Kamala D. Harris
Attorney General
State of California

ប័ណ្ណរបស់ Marsy និងធនធាន

រដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រនីញ៉ា មាត្រាទី 1 វគ្គទី 28(b) ប្រគល់សិទ្ធិខ្លះទៅឲ្យជនរងគ្រោះនៃបទឧក្រិដ្ឋ។ សិទ្ធិទាំងនោះរួមមាន :

1. **ភាពយុត្តិធម៌ និងការគោរព**
   ត្រូវបានប្រព្រឹត្តមកលើដោយសមគួរ និងដោយគោរពចំពោះភាពឯកជន និងភាពថ្លៃថ្នូររបស់គាត់ និងបាន រួចចាកពីការកំញើញ ការយាយី និងការរំលោភ សព្វទាំងក្នុងដំណើរការកាត់ក្តីបទឧក្រិដ្ឋ ឬយុវវ័យ។
2. **ការការពារ ពីអ្នកចុងចោទ**
   ត្រូវបានការពារដោយសមរម្យ ពីអ្នកចុងចោទ ព្រមទាំងមនុស្សដែលធ្វើការជំនួសអ្នកចុងចោទ។
3. **ការពិចារណាសុវត្ថិភាពជនរងគ្រោះ អំពីសណ្ឋានប្រាក់លោះ និងលក្ខខ័ណ្ឌការដោះលែង**
   ដើម្បីឲ្យបានពិចារណាអំពីសុវត្ថិភាពរបស់ជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះ ក្នុងការកំរិតចំនួនប្រាក់លោះ និងលក្ខខ័ណ្ឌការដោះលែងអ្នកចុងចោទ។
4. **វិធីការពារ អំពីការបើកសំដែងនូវព័ត៌មានសំងាត់**
   ដើម្បីការពារនូវការបើកសំដែងនៃព័ត៌មានសំងាត់ ឬឯកសារ ទៅឲ្យអ្នកចុងចោទ ឬមេធាវីរបស់អ្នកចុងចោទ ឬមនុស្សផ្សេងទៀតដែលធ្វើការជំនួសអ្នកចុងចោទ ដែលអាចបានប្រើដើម្បីរក ឬយាយីជនរងគ្រោះ គ្រួសាររបស់ជនរងគ្រោះ ឬបើកសំដែងការប្រាស្រ័យទាក់ទងជាសំងាត់ ដែលបានធ្វើក្នុងពេលព្យាបាលរោគា ឬការប្រឹក្សា ការព្យាបាល ឬបើមិនដូច្នេះទេ ស្ថិតក្រោមឯកសិទ្ធិ ឬភាពសំងាត់របស់ច្បាប់។
5. **ការបដិសេធន៍មិនធ្វើសំភាសន៍ ពីសំណាក់ស្មាក្តីខាងចុងចោទ**
   ដើម្បីបដិសេធមិនធ្វើសំភាសន៍ ឬការថ្លែងប្រកាសជាលាយលក្ខណ៍អក្សរ ឬការបើកបង្ហាញ តាមសំណើរបស់អ្នកចុងចោទ ឬមេធាវីរបស់អ្នកចុងចោទ ឬដោយមនុស្សផ្សេងទៀតដែលធ្វើ ការជំនួសអ្នកចុងចោទ និងដើម្បីដាក់លក្ខខ័ណ្ឌសមហេតុផល ទៅលើការធ្វើសំភាសន៍បែបនោះ ដើម្បីឲ្យជនរងគ្រោះនោះយល់ព្រម។
6. **ការប្រជុំជាមួយស្មាក្តីខាងដើមចោទ និងសេចក្តីជូនដំណឹងការផ្ទេរកម្មសិទ្ធិ មុនពេលជំនុំជំរះក្តី**
   ដើម្បីផ្តល់សេចក្តីជូនដំណឹងដោយសមហេតុផល និងប្រគល់ដោយសមហេតុផល ជាមួយភ្នាក់ងារស្មាក្តីខាងដើមចោទ ទៅតាមសំណូមពរ ស្តីពីការចាប់ខ្លួនអ្នកចុងចោទ បើសិនស្មាក្តីខាងដើមចោទ ដឹងអំពីបទចោទបានប្តឹង ឬការអនុម័តថាតើត្រូវបញ្ជូនអ្នក ចុងចោទមានទោសទៅប្រទេសដើម និងនៅពេលមានសំណូមពរត្រូវបានជំរាប និងបានជ្រួតជ្រាបអំពីការផ្ទេរកម្មសិទ្ធិអ្វីមួយ មុនពេលជំនុំជំរះក្តី។
7. **សេចក្តីជូនដំណឹងនៃវិធីកាត់ក្តី និងវត្តមាននៅពេលកាត់ក្តីជាសាធារណៈ**
   ដើម្បីផ្តល់សេចក្តីជូនដំណឹងដោយសមហេតុផល នូវវិធីកាត់ក្តីជាសាធារណៈទាំងអស់ រួមទាំងវិធីកាត់ក្តីពីការប្រព្រឹត្តិល្មើសច្បាប់ ទៅតាមសំណូមពរ នៅពេលដែលអ្នកចុងចោទ និងស្មាក្តីខាងដើមចោទ មានសិទ្ធិត្រូវមានវត្តមាន និងរាល់លក្ខខ័ណ្ឌការដោះលែងទាំងអស់ ឬវិធីកាត់ក្តីពីការដោះលែង បន្ទាប់ពី-ការកាត់ទោសផ្សេងទៀត និងត្រូវមានវត្តមាននៅគ្រប់វិធីកាត់ក្តីបែបនោះទាំងអស់។
8. **ការបង្ហាញមុខ នៅពេលវិធីកាត់ក្តីនៅតុលាការ និងការបញ្ចេញទស្សនៈ**
   ត្រូវបានឮ តាមសំណូមពរ នៅគ្រប់វិធីកាត់ក្តីអ្វីមួយ រួមទាំងវិធីកាត់ក្តីពីការប្រព្រឹត្តិល្មើសច្បាប់ ជាប់ពាក់ព័ន្ធការសំរេចដោះលែងបន្ទាប់ពី-ការចាប់ខ្លួន ឬចំឡើយរបស់អ្នកចុងចោទ ឬទោសវិនិច្ឆ័យ ឬការសំរេចដោះលែងបន្ទាប់ពី-ការកាត់ទោស ឬវិធីកាត់ក្តីអ្វីមួយ ដែលសិទ្ធិរបស់ជនរងគ្រោះកំពុងតែ មានរឿងរ៉ាវ។
9. **ការជំនុំជំរះក្តីលឿន និងការសំរេចសេចក្តីនៃរឿងក្តីរួសរាន់**
   ត្រូវមានការជំនុំជំរះក្តីលឿន និងដោយរួសរាន់ និងមានការសំរេចសេចក្តីនៃរឿងក្តីជាផ្តាច់ព្រ័ត្រ និងការកាត់ក្តីអ្វីមួយជាប់ទាក់ទងបន្ទាប់ពី-វិធីវិនិច្ឆ័យទោស។
10. **ការទំនុកបំរុងព័ត៌មាន ទៅឲ្យក្រសួងការល្បងខ្លួន**
    ដើម្បីផ្តល់ព័ត៌មាន ទៅឲ្យអ្នករដ្ឋការនៃក្រសួងការល្បងខ្លួន ដែលធ្វើការស៊ើបអង្កេត មុន-ពេលវិនិច្ឆ័យទោស ជាប់ពាក់ព័ន្ធទៅលើឥទ្ធិពលនៃបទល្មើស មានទៅលើជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះ ព្រមទាំងអនុសាសន៍អំពីទោសវិនិច្ឆ័យ នៅមុនពេលវិនិច្ឆ័យទោសអ្នកចុងចោទ។
11. **ទទួលរបាយការណ៍ មុន-ពេលវិនិច្ឆ័យទោស**
    ដើម្បីទទួលរបាយការណ៍ មុន-ពេលវិនិច្ឆ័យទោស ទៅតាមសំណូមពរ នៅពេលដែលមានចំពោះអ្នកចុងចោទ លើកលែងតែសំរាប់ផ្នែកបានធ្វើតាមភាពសំងាត់របស់ច្បាប់។
12. **ព័ត៌មានអំពីការជាប់ទោស ការវិនិច្ឆ័យទោស ការជាប់ព័ន្ធធនាគារ ការដោះលែង និងការរត់គេចខ្លួន**
    ត្រូវបានជ្រួតជ្រាបទៅតាមសំណូមពរ អំពីការជាប់ទោស ឬទោសវិនិច្ឆ័យ ឬទីកន្លែង និងពេលវេលានៃការជាប់ព័ន្ធធនាគារ ឬការផ្ទេរកម្មសិទ្ធិផ្សេងទៀតរបស់អ្នកចុងចោទឬអំពីខែថ្ងៃឆ្នាំនៃការដោះលែងអ្នកចុងចោទបានគ្រោងពេល និងការដោះលែងអ្នកចុងចោទ ឬអ្នកចុងចោទរត់គេចខ្លួនចេញពីទីឃុំឃាំង។
13. **សំណង**
    A. វាជាបំណងច្បាស់លាស់ របស់ប្រជាជនរដ្ឋកាលីហ្វ័រនីញ៉ា ថាមនុស្សទាំងអស់ដែលទទួលការខាតបង់ ដោយសារសកម្មភាពនៃឧក្រិដ្ឋកម្ម ត្រូវមានសិទ្ធិដើម្បី ស្វែងរក និងទទួលសំណង ពីមនុស្សដែលបាន ជាប់ទោសបទឧក្រិដ្ឋ ដែលបណ្តាលឲ្យជនរងគ្រោះមានការខាតបង់។
    B. សំណងត្រូវបានបញ្ជាឲ្យសង ពីអ្នកប្រព្រឹត្តខុសបានជាប់ទោសក្នុងគ្រប់ករណី ទោះបើការវិនិច្ឆ័យទោស ឬការផ្ទេរកម្មសិទ្ធិបានដាក់កំហិត ដែលជនរងគ្រោះបទឧក្រិដ្ឋមានការខាតបង់។
    C. ការបង់ប្រាក់កាស ឬប្រាក់កាស និងទ្រព្យសម្បត្តិទាំងអស់ដែលបានប្រមូលមក ពីមនុស្សណាម្នាក់ ដែលត្រូវបានបញ្ជាឲ្យសងសំណង នោះជាដំបូងត្រូវបង់តាមចំនួនបានបញ្ជាឲ្យសងសំណងទៅជនរងគ្រោះ។
14. **ការប្រគល់ទ្រព្យសម្បត្តិវិញ ដោយរួសរាន់**
    ត្រូវប្រគល់ទ្រព្យសម្បត្តិវិញដោយរួសរាន់ នៅពេលលែងត្រូវការធ្វើជាភស្តុតាងទៀត។

Cambodian

Kamala D. Harris
Attorney General
State of California

ប័ណ្ណរបស់ Marsy និងធនធាន

រដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រនីញ៉ា មាត្រាទី 1 វគ្គទី 28(b) ប្រគល់សិទ្ធិខ្លះទៅឲ្យជនរងគ្រោះនៃបទឧក្រិដ្ឋ។ សិទ្ធិទាំងនោះរួមមាន :

1. **ភាពយុត្តិធម៌ និងការគោរព**
   ត្រូវបានប្រព្រឹត្តមកលើដោយសមគួរ និងដោយគោរពចំពោះភាពឯកជន និងភាពថ្លៃថ្នូររបស់គាត់ និងបាន រួចចាកពីការកំញើញ ការយាយី និងការរំលោភ សព្វទាំងក្នុងដំណើរការកាត់ក្តីបទឧក្រិដ្ឋ ឬយុវវ័យ។
2. **ការការពារ ពីអ្នកចុងចោទ**
   ត្រូវបានការពារដោយសមរម្យ ពីអ្នកចុងចោទ ព្រមទាំងមនុស្សដែលធ្វើការជំនួសអ្នកចុងចោទ។
3. **ការពិចារណាសុវត្ថិភាពជនរងគ្រោះ អំពីសណ្ឋានប្រាក់លោះ និងលក្ខខ័ណ្ឌការដោះលែង**
   ដើម្បីឲ្យបានពិចារណាអំពីសុវត្ថិភាពរបស់ជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះ ក្នុងការកំរិតចំនួនប្រាក់លោះ និងលក្ខខ័ណ្ឌការដោះលែងអ្នកចុងចោទ។
4. **វិធីការពារ អំពីការបើកសំដែងនូវព័ត៌មានសំងាត់**
   ដើម្បីការពារនូវការបើកសំដែងនៃព័ត៌មានសំងាត់ ឬឯកសារ ទៅឲ្យអ្នកចុងចោទ ឬមេធាវីរបស់អ្នកចុងចោទ ឬមនុស្សផ្សេងទៀតដែលធ្វើការជំនួសអ្នកចុងចោទ ដែលអាចបានប្រើដើម្បីរក ឬយាយីជនរងគ្រោះ គ្រួសាររបស់ជនរងគ្រោះ ឬបើកសំដែងការប្រាស្រ័យទាក់ទងជាសំងាត់ ដែលបានធ្វើក្នុងពេលព្យាបាលរោគា ឬការប្រឹក្សា ការព្យាបាល ឬបើមិនដូច្នេះទេ ស្ថិតក្រោមឯកសិទ្ធិ ឬភាពសំងាត់របស់ច្បាប់។
5. **ការបដិសេធន៍មិនធ្វើសំភាសន៍ ពីសំណាក់ស្មាក្តីខាងចុងចោទ**
   ដើម្បីបដិសេធមិនធ្វើសំភាសន៍ ឬការថ្លែងប្រកាសជាលាយលក្ខណ៍អក្សរ ឬការបើកបង្ហាញ តាមសំណើរបស់អ្នកចុងចោទ ឬមេធាវីរបស់អ្នកចុងចោទ ឬដោយមនុស្សផ្សេងទៀតដែលធ្វើ ការជំនួសអ្នកចុងចោទ និងដើម្បីដាក់លក្ខខ័ណ្ឌសមហេតុផល ទៅលើការធ្វើសំភាសន៍បែបនោះ ដើម្បីឲ្យជនរងគ្រោះនោះយល់ព្រម។
6. **ការប្រជុំជាមួយស្មាក្តីខាងដើមចោទ និងសេចក្តីជូនដំណឹងការផ្ទេរកម្មសិទ្ធិ មុនពេលជំនុំជំរះក្តី**
   ដើម្បីផ្តល់សេចក្តីជូនដំណឹងដោយសមហេតុផល និងប្រគល់ដោយសមហេតុផល ជាមួយភ្នាក់ងារស្មាក្តីខាងដើមចោទ ទៅតាមសំណូមពរ ស្តីពីការចាប់ខ្លួនអ្នកចុងចោទ បើសិនស្មាក្តីខាងដើមចោទ ដឹងអំពីបទចោទបានប្តឹង ឬការអនុម័តថាតើត្រូវបញ្ជូនអ្នក ចុងចោទមានទោសទៅប្រទេសដើម និងនៅពេលមានសំណូមពរត្រូវបានជំរាប និងបានជ្រួតជ្រាបអំពីការផ្ទេរកម្មសិទ្ធិអ្វីមួយ មុនពេលជំនុំជំរះក្តី។
7. **សេចក្តីជូនដំណឹងនៃវិធីកាត់ក្តី និងវត្តមាននៅពេលកាត់ក្តីជាសាធារណៈ**
   ដើម្បីផ្តល់សេចក្តីជូនដំណឹងដោយសមហេតុផល នូវវិធីកាត់ក្តីជាសាធារណៈទាំងអស់ រួមទាំងវិធីកាត់ក្តីពីការប្រព្រឹត្តិល្មើសច្បាប់ ទៅតាមសំណូមពរ នៅពេលដែលអ្នកចុងចោទ និងស្មាក្តីខាងដើមចោទ មានសិទ្ធិត្រូវមានវត្តមាន និងរាល់លក្ខខ័ណ្ឌការដោះលែងទាំងអស់ ឬវិធីកាត់ក្តីពីការដោះលែង បន្ទាប់ពី-ការកាត់ទោសផ្សេងទៀត និងត្រូវមានវត្តមាននៅគ្រប់វិធីកាត់ក្តីបែបនោះទាំងអស់។
8. **ការបង្ហាញមុខ នៅពេលវិធីកាត់ក្តីនៅតុលាការ និងការបញ្ចេញទស្សនៈ**
   ត្រូវបានឮ តាមសំណូមពរ នៅគ្រប់វិធីកាត់ក្តីអ្វីមួយ រួមទាំងវិធីកាត់ក្តីពីការប្រព្រឹត្តិល្មើសច្បាប់ ជាប់ពាក់ព័ន្ធការសំរេចដោះលែងបន្ទាប់ពី-ការចាប់ខ្លួន ឬចំឡើយរបស់អ្នកចុងចោទ ឬទោសវិនិច្ឆ័យ ឬការសំរេចដោះលែងបន្ទាប់ពី-ការកាត់ទោស ឬវិធីកាត់ក្តីអ្វីមួយ ដែលសិទ្ធិរបស់ជនរងគ្រោះកំពុងតែ មានរឿងរ៉ាវ។
9. **ការជំនុំជំរះក្តីលឿន និងការសំរេចសេចក្តីនៃរឿងក្តីរួសរាន់**
   ត្រូវមានការជំនុំជំរះក្តីលឿន និងដោយរួសរាន់ និងមានការសំរេចសេចក្តីនៃរឿងក្តីជាផ្តាច់ព្រ័ត្រ និងការកាត់ក្តីអ្វីមួយជាប់ទាក់ទងបន្ទាប់ពី-វិធីវិនិច្ឆ័យទោស។
10. **ការទំនុកបំរុងព័ត៌មាន ទៅឲ្យក្រសួងការល្បងខ្លួន**
    ដើម្បីផ្តល់ព័ត៌មាន ទៅឲ្យអ្នករដ្ឋការនៃក្រសួងការល្បងខ្លួន ដែលធ្វើការស៊ើបអង្កេត មុន-ពេលវិនិច្ឆ័យទោស ជាប់ពាក់ព័ន្ធទៅលើឥទ្ធិពលនៃបទល្មើស មានទៅលើជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះ ព្រមទាំងអនុសាសន៍អំពីទោសវិនិច្ឆ័យ នៅមុនពេលវិនិច្ឆ័យទោសអ្នកចុងចោទ។
11. **ទទួលរបាយការណ៍ មុន-ពេលវិនិច្ឆ័យទោស**
    ដើម្បីទទួលរបាយការណ៍ មុន-ពេលវិនិច្ឆ័យទោស ទៅតាមសំណូមពរ នៅពេលដែលមានចំពោះអ្នកចុងចោទ លើកលែងតែសំរាប់ផ្នែកបានធ្វើតាមភាពសំងាត់របស់ច្បាប់។
12. **ព័ត៌មានអំពីការជាប់ទោស ការវិនិច្ឆ័យទោស ការជាប់ព័ន្ធធនាគារ ការដោះលែង និងការរត់គេចខ្លួន**
    ត្រូវបានជ្រួតជ្រាបទៅតាមសំណូមពរ អំពីការជាប់ទោស ឬទោសវិនិច្ឆ័យ ឬទីកន្លែង និងពេលវេលានៃការជាប់ព័ន្ធធនាគារ ឬការផ្ទេរកម្មសិទ្ធិផ្សេងទៀតរបស់អ្នកចុងចោទឬអំពីខែថ្ងៃឆ្នាំនៃការដោះលែងអ្នកចុងចោទបានគ្រោងពេល និងការដោះលែងអ្នកចុងចោទ ឬអ្នកចុងចោទរត់គេចខ្លួនចេញពីទីឃុំឃាំង។
13. **សំណង**
    A. វាជាបំណងច្បាស់លាស់ របស់ប្រជាជនរដ្ឋកាលីហ្វ័រនីញ៉ា ថាមនុស្សទាំងអស់ដែលទទួលការខាតបង់ ដោយសារសកម្មភាពនៃឧក្រិដ្ឋកម្ម ត្រូវមានសិទ្ធិដើម្បី ស្វែងរក និងទទួលសំណង ពីមនុស្សដែលបាន ជាប់ទោសបទឧក្រិដ្ឋ ដែលបណ្តាលឲ្យជនរងគ្រោះមានការខាតបង់។
    B. សំណងត្រូវបានបញ្ជាឲ្យសង ពីអ្នកប្រព្រឹត្តខុសបានជាប់ទោសក្នុងគ្រប់ករណី ទោះបើការវិនិច្ឆ័យទោស ឬការផ្ទេរកម្មសិទ្ធិបានដាក់កំហិត ដែលជនរងគ្រោះបទឧក្រិដ្ឋមានការខាតបង់។
    C. ការបង់ប្រាក់កាស ឬប្រាក់កាស និងទ្រព្យសម្បត្តិទាំងអស់ដែលបានប្រមូលមក ពីមនុស្សណាម្នាក់ ដែលត្រូវបានបញ្ជាឲ្យសងសំណង នោះជាដំបូងត្រូវបង់តាមចំនួនបានបញ្ជាឲ្យសងសំណងទៅជនរងគ្រោះ។
14. **ការប្រគល់ទ្រព្យសម្បត្តិវិញ ដោយរួសរាន់**
    ត្រូវប្រគល់ទ្រព្យសម្បត្តិវិញដោយរួសរាន់ នៅពេលលែងត្រូវការធ្វើជាភស្តុតាងទៀត។

Cambodian

15. សេចក្តីជូនដំណឹង អំពីវិធីលក្ខខ័ណ្ឌការដោះលែង និងការដោះលែងមានលក្ខខ័ណ្ឌ

ត្រូវបានជ្រួតជ្រាបអំពីវិធីលក្ខខ័ណ្ឌការដោះទាំងអស់ ដើម្បីចូលរួមក្នុងដំណើរនៃលក្ខខ័ណ្ឌការដោះលែង ឬផ្តល់ព័ត៌មានទៅឲ្យអាជ្ញាធរត្រួតលក្ខខ័ណ្ឌការដោះលែង ប្រយោជន៍ឲ្យបានពិចារណានៅមុនពេលមានលក្ខខ័ណ្ឌការដោះលែងជនប្រព្រឹត្តិល្មើស ព្រមទាំងត្រូវបានជំរាបទៅតាមសំណូមពរ អំពីលក្ខខ័ណ្ឌការដោះលែង ឬការដោះលែងផ្សេងទៀត នូវជនប្រព្រឹត្តិល្មើស។

16. សុវត្ថិភាពរបស់ជនរងគ្រោះ និងសាធារណជន គឺជាកត្តានៃលក្ខខ័ណ្ឌការដោះលែង

ដើម្បីឲ្យបានពិចារណា អំពីសុវត្ថិភាពសំរាប់ជនរងគ្រោះ គ្រួសាររបស់ជនរងគ្រោះ និងសាធារណជនទូទៅមុនពេលមានលក្ខខ័ណ្ឌការដោះលែងអ្វីមួយ ឬការសំរេចដោះលែងផ្សេងទៀត បានធ្វើបន្ទាប់ពី-ការវិនិច្ឆ័យទោស។

17. ព័ត៌មានអំពីសិទ្ធិទាំង 16 នេះ

ដើម្បីឲ្យបានជ្រួតជ្រាប អំពីសិទ្ធិដែលបានរាយតាមលំដាប់ ក្នុងប្រយោគ (1) រហូតដល់ (16)។

ផ្នែកសេវាជនរងគ្រោះរបស់អគ្គមេធាវី – ផ្តល់ព័ត៌មានសំរាប់ជនរងគ្រោះ/សាក្សីក្នុងតំបន់, ផ្តល់ធនធានព័ត៌មានតាមភូមិសាស្ត្រ និងស្ថានភាពការតវ៉ា សំរាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ។ ដើម្បីទទួលធនធានព័ត៌មាន ស្តីពីមណ្ឌលជំនួយសាក្សីក្នុងតំបន់ ឬដើម្បីស្នើសុំ ការជំរាបដំណឹងអំពីស្ថានភាពការតវ៉ា សូមទាក់ទង : **1-877-433-9069**។ សំរាប់ព័ត៌មានបន្ថែម អំពីច្បាប់របស់ Marsy សូមមើលវ៉ិបសៃត៍របស់អគ្គមេធាវីនៅ :

www.ag.ca.gov/victimservices

****

ធនធានបន្ថែម

អគ្គមេធាវីមិនយល់ព្រម ឬមានការទទួលខុសត្រូវអ្វី ឬមានការត្រួតត្រាទៅលើទស្សនៈ សេវា និងព័ត៌មានរបស់អង្គការ និងភ្នាក់ងារ ទាំងនេះឡើយ។

កម្មវិធីសងប្រាក់ឲ្យជនរងគ្រោះ – ជួយជនរងគ្រោះនៃ : ការវាយដំ, ការបើករថយន្តស្រវឹងស្រា, ការរំលោភកាម, ការធ្វើបាបក្មេង, ការសំឡាប់មនុស្ស, ការឈ្លបចាប់ខ្លួន, អំពើហិង្សាក្នុងគ្រួសារ, ការប្លន់និងជួញមនុស្ស។ ការសងប្រាក់ឲ្យជនរងគ្រោះអាចជួយបង់ថ្លៃ : ការប្រឹក្សាសុខភាពអារម្មណ៍, ដំឡៃបុណ្យសព, ការបាត់បង់ប្រាក់ចំណូល, ការសំអាតកន្លែងឧក្រិដ្ឋកម្ម, ការផ្លាស់លំនៅ, វិក្កយប័ត្រថ្លៃពេទ្យ និងធ្មេញ។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងកម្មវិធី សាក្សីជនរងគ្រោះ (Victim Witness) ឬការសងប្រាក់ ឲ្យជនរងគ្រោះ (Victim Compensation) និងគណៈបណ្តឹងសំណងរដ្ឋាភិបាល (Government Claims Board) នៅក្នុងតំបន់របស់អ្នក : **1-800-777-9229**

www.vcgcb.ca.gov/victims

ក្រសួងកែខៃខ្លួន និងការស្តារលទ្ធភាពរដ្ឋកាលីហ្វ័រនីញ៉ា, ការិយាល័យនៃជនរងគ្រោះ និងសិទ្ធិអ្នកគង់វង្សជីវិត និងសេវា (CA Dept. of Corrections and Rehabilitation, Office of Victim & Survivor Rights & Services) – ផ្តល់ព័ត៌មានអំពីការដោះលែងឧក្រិដ្ឋជន, សំណង, លក្ខណៈលក្ខខ័ណ្ឌការដោះលែង និងសវនាការនៃលក្ខខ័ណ្ឌការដោះលែង នៅពេលឧក្រិដ្ឋជនបានជាប់ទោសនៅក្នុងពន្ធនាគារ។

1-877-256-6877 *www.cdcr.ca.gov/victim_services*

សាលាច្បាប់ McGeorge - មណ្ឌលធនធានជនរងគ្រោះនៃបទឧក្រិដ្ឋ (Victims of Crime Resource Center) – ផ្តល់ធនធានសំរាប់ជនរងគ្រោះ តាមតំបន់ភូមិសាស្ត្ររបស់គេ ព្រមទាំងផ្តល់ព័ត៌មានស្តីពីសំណង, បណ្តឹងពលរដ្ឋ, អំពើហិង្សាក្នុងគ្រួសារ, ការធ្វើបាបមនុស្សចាស់, ការធ្វើបាបក្មេង, ការធ្វើបាបប្រឆាំងនឹងជនពិការ, សិទ្ធិរបស់ជនរងគ្រោះ និងការសងប្រាក់។ **1-800-Victims** *www.1800victims.org*

លេខពិសេសជាតិ នៃអំពើហិង្សាក្នុងគ្រួសារ – លេខពិសេស 24 ម៉ោង សំរាប់ធនធាននៃអំពើហិង្សាក្នុងគ្រួសារ។

1-800-799-SAFE (TTY) 1-800-787-3224 *www.ndvh.org*

ព័ត៌មានទាក់ទងទៅខោនធី សំរាប់សេវាការពារមនុស្សពេញវ័យ (ការធ្វើបាបមនុស្សចាស់) – វ៉ិបសៃត៍មានចុះរាយលេខពិសេស 24 ម៉ោង សំរាប់ខោនធីនិមួយៗក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

www.cdss.ca.gov/agedblinddisabled/PG2300.htm

លេខពិសេសជាតិ នៃការធ្វើបាបក្មេង – ផ្តល់ការព្យាបាល និងការពារនូវការធ្វើបាបក្មេង។

1-800-4-A-CHILD *www.childhelp.org/pages/hotline-services*

លេខពិសេសបណ្តាញជាតិ នៃការរំលោភ ការធ្វើបាប និងការស្មន់នឹងពូជខ្លួនឯង – ផ្តល់ការប្រឹក្សាជាសំងាត់ដោយឥតគិតថ្លៃ សំរាប់ជនរងគ្រោះនៃការរំលោភកាម។ **1-800-656-HOPE** *www.rainn.org*

លេខពិសេសជាតិ នៃមណ្ឌលធនធានការជួញមនុស្ស – លេខពិសេស 24 ម៉ោង សំរាបឱ្យវាទការរាយការណ៍, ការទាក់ទងភ្នាក់ងារ ក្នុងតំបន់ប្រឆាំងនឹងការជួញមនុស្ស និងស្នើសុំព័ត៌មាន។

1-888-373-7888 *www.traffickingresourcecenter.org*

សេវាបណ្តាក់សាររដ្ឋកាលីហ្វ័រនីញ៉ា : សំរាប់អ្នកទូរស័ព្ទមកដែលអន់សំដី ថ្លង់ និងស្តាប់មិនសូវឮ : **ចុចលេខ 711**។ **TTY/HCO/VCO ទៅសំឡេងសំរាប់ភាសាអង់គ្លេស :** 1-800-735-2929 **និងសំរាប់ភាសាអេស្ប៉ាញ៉ុល :** 1-800-855-3000។ **សំឡេងទៅ TTY/VCO/HCO សំរាប់ភាសាអង់គ្លេស :** 1-800-735-2922 **និង សំរាប់ភាសាអេស្ប៉ាញ៉ុល :** 1-800-855-3000។ **ពី ឬទៅ សំដី ទៅសំដី – ភាសាអង់គ្លេស និងអេស្ប៉ាញ៉ុល :** 1-800-854-7784។

****

ពាក្យ "ជនរងគ្រោះ" គឺបានឲ្យអត្ថន័យនៅក្រោមរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រនីញ៉ាថាជា "បុគ្គលម្នាក់បានរងវេទនាផ្ទាល់ ឬត្រូវបានគំរាមកំហែងទៅលើរូបកាយ ផ្លូវចិត្ត ឬបន្លំប្រាក់កាស ជាលទ្ធផលនៃការប្រព្រឹត្តិ ឬបានប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬអំពើប្រព្រឹត្តិបទល្មើស។ ពាក្យ "ជនរងគ្រោះ" ក៏រួមមានប្តីឬប្រពន្ធ, មាតាបិតា, កូន, បងប្អូន, ឬអាណាព្យាបាលរបស់បុគ្គលម្នាក់, ហើយក៏រួមមាន អ្នកតំណាងពេញច្បាប់នៃជនរងគ្រោះបទឧក្រិដ្ឋ ដែលបានស្លាប់, ក្មេងអាយុមិនទាន់ពេញច្បាប់, ឬជនគ្មានសមត្ថភាពខាងរូបកាយ ឬផ្លូវចិត្ត។ ពាក្យ "ជនរងគ្រោះ" មិនរាប់បញ្ចូលនូវបុគ្គលនៅក្នុងការថែគ្រប់គ្រងសំរាប់ការប្រព្រឹត្តិល្មើស, បុគ្គលជាប់ចោទ, ឬបុគ្គលដែលតុលាការរកឃើញថានឹងមិនប្រព្រឹត្ត ក្នុងផលប្រយោជន៍ល្អនៃជនរងគ្រោះជាក្មេងអាយុមិនទាន់ពេញច្បាប់។" (កាលី. រដ្ឋធម្មនុញ្ញ មាត្រា I, § 28(e)។)

ជនរងគ្រោះ, មេធាវីដែលជនរងគ្រោះបានជួល, អ្នកតំណាងពេញច្បាប់នៃជនរងគ្រោះ, ឬមេធាវីចោទប្រកាន់ទោសទៅតាមសំណើនៃជនរងគ្រោះ, អាចនឹងបង្ខំឲ្យអនុវត្តនូវសិទ្ធិខាងលើ នៅក្នុងការជំនុំជំរះណាមួយ ឬសាលាឧទ្ធរណ៍ ដែលមានសិទ្ធិអាជ្ញាទៅលើរឿងក្តីជារឿងរ៉ាវនៃសិទ្ធិ។ តុលាការត្រូវប្រព្រឹត្តយ៉ាងរួសរាន់ទៅលើសំណើបែបនោះ។ (កាលី. រដ្ឋធម្មនុញ្ញ មាត្រា I, § 28(c)(1)។)

ផ្នែកសេវាជនរងគ្រោះ 06/2014

Funding is made possible through the United States Department of Justice, Victims of Crime Act, 2013-VA-GX-0004.

15. សេចក្តីជូនដំណឹង អំពីវិធីលក្ខខ័ណ្ឌការដោះលែង និងការដោះលែងមានលក្ខខ័ណ្ឌ

ត្រូវបានជ្រួតជ្រាបអំពីវិធីលក្ខខ័ណ្ឌការដោះទាំងអស់ ដើម្បីចូលរួមក្នុងដំណើរនៃលក្ខខ័ណ្ឌការដោះលែង ឬផ្តល់ព័ត៌មានទៅឲ្យអាជ្ញាធរត្រួតលក្ខខ័ណ្ឌការដោះលែង ប្រយោជន៍ឲ្យបានពិចារណានៅមុនពេលមានលក្ខខ័ណ្ឌការដោះលែងជនប្រព្រឹត្តិល្មើស ព្រមទាំងត្រូវបានជំរាបទៅតាមសំណូមពរ អំពីលក្ខខ័ណ្ឌការដោះលែង ឬការដោះលែងផ្សេងទៀត នូវជនប្រព្រឹត្តិល្មើស។

16. សុវត្ថិភាពរបស់ជនរងគ្រោះ និងសាធារណជន គឺជាកត្តានៃលក្ខខ័ណ្ឌការដោះលែង

ដើម្បីឲ្យបានពិចារណា អំពីសុវត្ថិភាពសំរាប់ជនរងគ្រោះ គ្រួសាររបស់ជនរងគ្រោះ និងសាធារណជនទូទៅមុនពេលមានលក្ខខ័ណ្ឌការដោះលែងអ្វីមួយ ឬការសំរេចដោះលែងផ្សេងទៀត បានធ្វើបន្ទាប់ពី-ការវិនិច្ឆ័យទោស។

17. ព័ត៌មានអំពីសិទ្ធិទាំង 16 នេះ

ដើម្បីឲ្យបានជ្រួតជ្រាប អំពីសិទ្ធិដែលបានរាយតាមលំដាប់ ក្នុងប្រយោគ (1) រហូតដល់ (16)។

ផ្នែកសេវាជនរងគ្រោះរបស់អគ្គមេធាវី – ផ្តល់ព័ត៌មានសំរាប់ជនរងគ្រោះ/សាក្សីក្នុងតំបន់, ផ្តល់ធនធានព័ត៌មានតាមភូមិសាស្ត្រ និងស្ថានភាពការតវ៉ា សំរាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ។ ដើម្បីទទួលធនធានព័ត៌មាន ស្តីពីមណ្ឌលជំនួយសាក្សីក្នុងតំបន់ ឬដើម្បីស្នើសុំ ការជំរាបដំណឹងអំពីស្ថានភាពការតវ៉ា សូមទាក់ទង : **1-877-433-9069**។ សំរាប់ព័ត៌មានបន្ថែម អំពីច្បាប់របស់ Marsy សូមមើលវ៉ិបសៃត៍របស់អគ្គមេធាវីនៅ :

www.ag.ca.gov/victimservices

****

ធនធានបន្ថែម

អគ្គមេធាវីមិនយល់ព្រម ឬមានការទទួលខុសត្រូវអ្វី ឬមានការត្រួតត្រាទៅលើទស្សនៈ សេវា និងព័ត៌មានរបស់អង្គការ និងភ្នាក់ងារ ទាំងនេះឡើយ។

កម្មវិធីសងប្រាក់ឲ្យជនរងគ្រោះ – ជួយជនរងគ្រោះនៃ : ការវាយដំ, ការបើករថយន្តស្រវឹងស្រា, ការរំលោភកាម, ការធ្វើបាបក្មេង, ការសំឡាប់មនុស្ស, ការឈ្លបចាប់ខ្លួន, អំពើហិង្សាក្នុងគ្រួសារ, ការប្លន់និងជួញមនុស្ស។ ការសងប្រាក់ឲ្យជនរងគ្រោះអាចជួយបង់ថ្លៃ : ការប្រឹក្សាសុខភាពអារម្មណ៍, ដំឡៃបុណ្យសព, ការបាត់បង់ប្រាក់ចំណូល, ការសំអាតកន្លែងឧក្រិដ្ឋកម្ម, ការផ្លាស់លំនៅ, វិក្កយប័ត្រថ្លៃពេទ្យ និងធ្មេញ។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងកម្មវិធី សាក្សីជនរងគ្រោះ (Victim Witness) ឬការសងប្រាក់ ឲ្យជនរងគ្រោះ (Victim Compensation) និងគណៈបណ្តឹងសំណងរដ្ឋាភិបាល (Government Claims Board) នៅក្នុងតំបន់របស់អ្នក : **1-800-777-9229**

www.vcgcb.ca.gov/victims

ក្រសួងកែខៃខ្លួន និងការស្តារលទ្ធភាពរដ្ឋកាលីហ្វ័រនីញ៉ា, ការិយាល័យនៃជនរងគ្រោះ និងសិទ្ធិអ្នកគង់វង្សជីវិត និងសេវា (CA Dept. of Corrections and Rehabilitation, Office of Victim & Survivor Rights & Services) – ផ្តល់ព័ត៌មានអំពីការដោះលែងឧក្រិដ្ឋជន, សំណង, លក្ខណៈលក្ខខ័ណ្ឌការដោះលែង និងសវនាការនៃលក្ខខ័ណ្ឌការដោះលែង នៅពេលឧក្រិដ្ឋជនបានជាប់ទោសនៅក្នុងពន្ធនាគារ។

1-877-256-6877 *www.cdcr.ca.gov/victim_services*

សាលាច្បាប់ McGeorge - មណ្ឌលធនធានជនរងគ្រោះនៃបទឧក្រិដ្ឋ (Victims of Crime Resource Center) – ផ្តល់ធនធានសំរាប់ជនរងគ្រោះ តាមតំបន់ភូមិសាស្ត្ររបស់គេ ព្រមទាំងផ្តល់ព័ត៌មានស្តីពីសំណង, បណ្តឹងពលរដ្ឋ, អំពើហិង្សាក្នុងគ្រួសារ, ការធ្វើបាបមនុស្សចាស់, ការធ្វើបាបក្មេង, ការធ្វើបាបប្រឆាំងនឹងជនពិការ, សិទ្ធិរបស់ជនរងគ្រោះ និងការសងប្រាក់។ **1-800-Victims** *www.1800victims.org*

លេខពិសេសជាតិ នៃអំពើហិង្សាក្នុងគ្រួសារ – លេខពិសេស 24 ម៉ោង សំរាប់ធនធាននៃអំពើហិង្សាក្នុងគ្រួសារ។

1-800-799-SAFE (TTY) 1-800-787-3224 *www.ndvh.org*

ព័ត៌មានទាក់ទងទៅខោនធី សំរាប់សេវាការពារមនុស្សពេញវ័យ (ការធ្វើបាបមនុស្សចាស់) – វ៉ិបសៃត៍មានចុះរាយលេខពិសេស 24 ម៉ោង សំរាប់ខោនធីនិមួយៗក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

www.cdss.ca.gov/agedblinddisabled/PG2300.htm

លេខពិសេសជាតិ នៃការធ្វើបាបក្មេង – ផ្តល់ការព្យាបាល និងការពារនូវការធ្វើបាបក្មេង។

1-800-4-A-CHILD *www.childhelp.org/pages/hotline-services*

លេខពិសេសបណ្តាញជាតិ នៃការរំលោភ ការធ្វើបាប និងការស្មន់នឹងពូជខ្លួនឯង – ផ្តល់ការប្រឹក្សាជាសំងាត់ដោយឥតគិតថ្លៃ សំរាប់ជនរងគ្រោះនៃការរំលោភកាម។ **1-800-656-HOPE** *www.rainn.org*

លេខពិសេសជាតិ នៃមណ្ឌលធនធានការជួញមនុស្ស – លេខពិសេស 24 ម៉ោង សំរាបឱ្យវាទការរាយការណ៍, ការទាក់ទងភ្នាក់ងារ ក្នុងតំបន់ប្រឆាំងនឹងការជួញមនុស្ស និងស្នើសុំព័ត៌មាន។

1-888-373-7888 *www.traffickingresourcecenter.org*

សេវាបណ្តាក់សាររដ្ឋកាលីហ្វ័រនីញ៉ា : សំរាប់អ្នកទូរស័ព្ទមកដែលអន់សំដី ថ្លង់ និងស្តាប់មិនសូវឮ : **ចុចលេខ 711**។ **TTY/HCO/VCO ទៅសំឡេងសំរាប់ភាសាអង់គ្លេស :** 1-800-735-2929 **និងសំរាប់ភាសាអេស្ប៉ាញ៉ុល :** 1-800-855-3000។ **សំឡេងទៅ TTY/VCO/HCO សំរាប់ភាសាអង់គ្លេស :** 1-800-735-2922 **និង សំរាប់ភាសាអេស្ប៉ាញ៉ុល :** 1-800-855-3000។ **ពី ឬទៅ សំដី ទៅសំដី – ភាសាអង់គ្លេស និងអេស្ប៉ាញ៉ុល :** 1-800-854-7784។

****

ពាក្យ "ជនរងគ្រោះ" គឺបានឲ្យអត្ថន័យនៅក្រោមរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រនីញ៉ាថាជា "បុគ្គលម្នាក់បានរងវេទនាផ្ទាល់ ឬត្រូវបានគំរាមកំហែងទៅលើរូបកាយ ផ្លូវចិត្ត ឬបន្លំប្រាក់កាស ជាលទ្ធផលនៃការប្រព្រឹត្តិ ឬបានប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬអំពើប្រព្រឹត្តិបទល្មើស។ ពាក្យ "ជនរងគ្រោះ" ក៏រួមមានប្តីឬប្រពន្ធ, មាតាបិតា, កូន, បងប្អូន, ឬអាណាព្យាបាលរបស់បុគ្គលម្នាក់, ហើយក៏រួមមាន អ្នកតំណាងពេញច្បាប់នៃជនរងគ្រោះបទឧក្រិដ្ឋ ដែលបានស្លាប់, ក្មេងអាយុមិនទាន់ពេញច្បាប់, ឬជនគ្មានសមត្ថភាពខាងរូបកាយ ឬផ្លូវចិត្ត។ ពាក្យ "ជនរងគ្រោះ" មិនរាប់បញ្ចូលនូវបុគ្គលនៅក្នុងការថែគ្រប់គ្រងសំរាប់ការប្រព្រឹត្តិល្មើស, បុគ្គលជាប់ចោទ, ឬបុគ្គលដែលតុលាការរកឃើញថានឹងមិនប្រព្រឹត្ត ក្នុងផលប្រយោជន៍ល្អនៃជនរងគ្រោះជាក្មេងអាយុមិនទាន់ពេញច្បាប់។" (កាលី. រដ្ឋធម្មនុញ្ញ មាត្រា I, § 28(e)។)

ជនរងគ្រោះ, មេធាវីដែលជនរងគ្រោះបានជួល, អ្នកតំណាងពេញច្បាប់នៃជនរងគ្រោះ, ឬមេធាវីចោទប្រកាន់ទោសទៅតាមសំណើនៃជនរងគ្រោះ, អាចនឹងបង្ខំឲ្យអនុវត្តនូវសិទ្ធិខាងលើ នៅក្នុងការជំនុំជំរះណាមួយ ឬសាលាឧទ្ធរណ៍ ដែលមានសិទ្ធិអាជ្ញាទៅលើរឿងក្តីជារឿងរ៉ាវនៃសិទ្ធិ។ តុលាការត្រូវប្រព្រឹត្តយ៉ាងរួសរាន់ទៅលើសំណើបែបនោះ។ (កាលី. រដ្ឋធម្មនុញ្ញ មាត្រា I, § 28(c)(1)។)

ផ្នែកសេវាជនរងគ្រោះ 06/2014

Funding is made possible through the United States Department of Justice, Victims of Crime Act, 2013-VA-GX-0004.